# ម៉ាក់!  កូនសុំទោស

(បទបន្ទោលកាក)

| | |
|---|---|
| កូនលើកហត្ថា | ប្រកាសវាចាសច្ចៈ |
| គារវៈអ្នកម៉ាក់ | ម្ចាស់ថ្លៃដាក់លើសិរសា ។ |
| តាំងពីកើតមក | ម្ដាយជាជម្រកសុខា |
| ថ្នាក់ថ្នមរក្សា | ទុក្ខាទាំងឡាយគ្មានទេ ។ |
| ពីតូចដល់ធំ | ម្ដាយតែងអប់រំគ្នាន់គ្នេរ |
| មិនឱ្យកូនវេ | ខុសចាកគន្លងប្រពៃ ។ |
| កូនមិនដែលស្ដាប់ | យកសព្ទមាតាស្រដី |
| កាន់ចិត្តអប្រិយ | ហិចហើរដើរលេងពាលា ។ |
| គប់មិត្តមិនល្អ | ត្រាច់ចរតាមទីនានា |
| បង្ហិនទ្រព្យា | ស៊ីចាយមិនស្ដាយស្រណោះ ។ |
| បង្កបញ្ហា | ឱ្យម្ដាយទុក្ខាក្រៀមក្រោះ |
| ភ្លើតភ្លើនបង់បោះ | ចោលអស់នូវការសិក្សា ។ |
| លង់ល្បែងលោកិយ | វក់ញៀនចំណីតណ្ហា |
| គ្មានពិចារណា | បណ្ដោយតាមចិត្តចំណង់ ។ |
| ពេលនេះទឹកភ្នែក | ហូរជ្រែកស្រោចស្រប់អស់អង្គ |
| បាត់ក្ដីផូរផង់ | ស្មើរបង់អស់ទាំងសង្ខារ ។ |
| ផលអាវ៉ាសែ | បានផ្ដល់ដូចពាក្យម៉ែថា |
| អោយវងខ្លោចផ្សា | ទាំងកាយចិន្ដាក្រៀមក្រោះ ។ |
| ឥឡូវកូនយល់ | ពាក្យពេចន៍អ្នកម្ដាយទាំងអស់ |
| យល់ឥតចន្លោះ | គ្មានទីធ្លោយថ្លោះទៀតទេ ។ |
| តូចចិត្តត្បិតខ្ញុំ | ចោលការអប់រំអោយវេ |
| អាណិតព្រះមេ | អត់ធ្មត់គ្មានស្ដីអ្វីសោះ ។ |

កិច្ចការស្រាលធ្ងន់ អ្នកម្តាយអត់ធន់ទាំងអស់
កាយាស្ទើរខ្សោះ ក៏ព្រោះអោយកូនបានសុខ ។
ពីថ្ងៃនេះទៅ កូននឹងមិននៅសំកុក
មិនបង្កស្មុគ រំអុកធ្វើបាបចិត្តម្តាយ ។
នឹងខំសិក្សា ស្វែងរកកិច្ចការទាំងឡាយ
ទោះបីជិតឆ្ងាយ មិនណាយមិនរាក្នុងចិត្ត។
តាំងចិត្តធ្វើល្អ ជាបុត្របវរប្រណីត
សងគុណម៉ែពិត ជីវិតរកសុខមង្គល ។
ម៉ែអើយអ្នកម៉ែ សូមម៉ែផុតទុក្ខអំពល់
គុណទោសកូនយល់ និមល អប្រិយ ស្គាល់ច្បាស់ ។
សូមអ្នកមានគុណ ជាទេវតាមុនក្នុងផ្ទះ
បានផុតស្រលះ ជាសះក្តីព្រួយចំបែង ។
ពាក្យថាកូនល្អ ខ្ញុំនឹងបន្តតំណែង
វាចាជាក់ស្តែង មិនក្លែងបំភាន់ម៉ែឡើយ ។
កូនសូមញញឹម ផ្តល់ក្តីសង្ឃឹមអោយហើយ
មិនទៅកន្ទើយ រកត្រើយជូនវង្សត្រកូល ។
ស្តាប់ពាក្យប្រដៅ ពេលអ្នកម៉ែហៅអោយចូល
ទូន្មានប្រមូល ជាស្នូលមង្គលជីវិត ។
ចិត្តពាលឫស្យា កូនលែងត្រូវការអោយជិត
អបាយមុខពិត គួបគិតវៀរចាកសន្តាន ។
សូមអោយម្តាយខ្ញុំ រស់បានសុខដុមថ្កើងថ្កាន
សុខភាពក្នុងប្រាណ ម៉ែបានសុខសាន្តរៀងអើយ ។

*(១៥ មិថុនា ២០០៨)*

*ភិក្ខុ ស្វាត សាលឿម*